**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣*៤

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ១៦៦ ស.អ.យ.ប្រក

ថ្ងៃ ចន្ទ ១០រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២០

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់នីតិវិធី និងដំណើរការអនុវត្ត កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២៤៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតអនុគណៈកម្មាធិការជំនួយសង្គម
- បានឃើញអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

# សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នីតិវិធី និងដំណើរការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ប្រការ២.-**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធអាចប្រើប្រាស់នីតិវិធី និងដំណើរការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដើម្បីផ្តល់ការគាំទ្រការអនុវត្តកម្មវិធី ក្នុងការគាំពារ និងរក្សាលំនឹងជីវភាពរស់នៅរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ នៅក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ប្រការ៣.-**

ឯកសារស្តីពីនីតិវិធី និងដំណើរការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩នេះ រៀបចំឡើងក្នុងគោលបំណងកំណត់អំពីនីតិវិធី និងយន្តការគ្រប់គ្រងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ នៅក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយបញ្ជាក់អំពីដំណើរការ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ក្នុងការអនុវត្តកម្មវិធីឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៤.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានជាតិសង្គមកិច្ច ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

វង សូត

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាជាតិគាំពារសង្គម
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជ្រាប"
- ដូចប្រការ៤
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា

SOCIAL PROTECTION IN CAMBODIA
ក្រុមប្រឹក្សាជាតិគាំពារសង្គម

# នីតិវិធី និងដំណើរការនៃការអនុវត្ត កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

នាយកដ្ឋានសុខុមាលភាពសង្គម

ខែមិថុនា ឆ្នាំ២០២០

# មាតិកា


**សេចក្តីផ្តើម ........ ១**

**ជំពូកទី១. ដំណើរការនៃការអនុវត្តកម្មវិធី ........ ២**

១.១. គោលបំណងនៃការផ្ទៀងផ្ទាត់ឈ្មោះ ........ ២

១.២. លក្ខខណ្ឌនៃការផ្ទៀងផ្ទាត់ឈ្មោះ ........ ២

១.៣. ការឧបត្ថម្ភដល់អ្នកទទួលផល ........ ២

១.៤. ការផ្ទៀងផ្ទាត់ឈ្មោះ និងការបើកផ្តល់លើកដំបូង ........ ៣

១.៥. ការបើកផ្តល់លើកបន្ទាប់ ........ ៤

**ជំពូកទី២. ការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី ........ ៥**

២.១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ........ ៥

២.២. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ........ ៥

២.៣. ឃុំ សង្កាត់ ........ ៥

**ជំពូកទី៣. យន្តការដោះស្រាយបណ្តឹងតវ៉ា ........ ៦**

៣.១. យន្តការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកទទួលផល ........ ៦

៣.២. ការដោះស្រាយការប្រព្រឹត្តមិនត្រឹមត្រូវរបស់មន្ត្រីកម្មវិធី ........ ៧

៣.៣. ការដោះស្រាយការប្រព្រឹត្តមិនត្រឹមត្រូវរបស់ស្ថាប័នបើកផ្តល់ ........ ៧

**ជំពូកទី៤. យន្តការគាំទ្រការអនុវត្តកម្មវិធី ........ ៨**

៤.១. ស្ថាប័នថ្នាក់ជាតិ ........ ៨

៤.២. ស្ថាប័នថ្នាក់ក្រោមជាតិ ........ ៩

**ជំពូកទី៥. របៀបប្រើប្រាស់មុខងារបន្ថែមរបស់អែប(App) ........ ១១**

៥.១. ការផ្ទៀងផ្ទាត់ឈ្មោះ និងការបើកផ្តល់លើកដំបូង ........ ១១

៥.២. បណ្តឹងតវ៉ារបស់អ្នកទទួលផល ........ ១៣

# សេចក្តីផ្តើម

ប្រទេសកម្ពុជាត្រូវបានរកឃើញជំងឺកូវីដ-១៩ ជាលើកដំបូងនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ហើយត្រូវបានរកឃើញជាបន្តបន្ទាប់។ ការរីករាលដាលនៃជំងឺកូវីដ-១៩ បានកើតមានជាសកល និងបន្តអូសបន្លាយមកដល់បច្ចុប្បន្ននេះ ដែលបានធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ចពិភពលោក និងប្រទេសកម្ពុជា ជាពិសេសលើវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងស្បែកជើង និងវិស័យសេវាកម្ម(ទេសចរណ៍ សណ្ឋាគារ និងភោជនីយដ្ឋាន) ហើយផលប៉ះពាល់នេះបង្កឱ្យមានការបាត់បង់ការងារធ្វើ និងការធ្លាក់ចុះប្រាក់ចំណូលជាលំដាប់ ជាពិសេស ប្រជាជនក្រីក្រ និងងាយរងគ្រោះដែលមានចំណូលទាប។

ផ្អែកតាមលទ្ធផលអង្កេតរហ័សរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងខែមិថុនា ឆ្នាំ២០២០ ស្តីពីស្ថានភាពនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ និងស្ថានភាពរបស់អ្នកទទួលផល ក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ បានបង្ហាញថា អ្នកទទួលផលរបស់កម្មវិធីភាគច្រើនបានបាត់បង់មុខរបរ និងប្រាក់ចំណូល(៤០.៥%) ដែលក្នុងនោះ អ្នកទទួលផលបានកាត់បន្ថយការចំណាយមិនចាំបាច់មួយចំនួន(៤៧.១%) និងការចំណាយចាំបាច់មួយចំនួន(២២.១%)លើការអប់រំ សុខភាព និងស្បៀងអាហារ។

ដើម្បីជួយសម្រាលការលំបាករបស់ប្រជាជន ដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ជាពិសេសប្រជាជនដែលមានចំណូលទាប និងងាយរងគ្រោះ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដើម្បីផ្តល់កិច្ចគាំពារ និងរក្សាលំនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និងងាយរងគ្រោះ នៅក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។ កម្មវិធីនេះ ប្រើប្រាស់យន្តការដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលដឹកនាំ គ្រប់គ្រង និងអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយសហការជាមួយនឹងក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងផែនការ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។៚

# ជំពូកទី១
# ដំណើរការនៃការអនុវត្តកម្មវិធី

## ១.១. គោលបំណងនៃការផ្ទៀងផ្ទាត់ឈ្មោះ

ការផ្ទៀងផ្ទាត់ឈ្មោះ មានគោលបំណងឱ្យគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌កម្រិតភាពក្រីក្រ១ ឬកម្រិតភាពក្រីក្រ២ ដែលមានសុពលភាព អាចផ្ទៀងផ្ទាត់ឈ្មោះ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាននៅតាមឃុំ សង្កាត់ ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីកម្មវិធី។

## ១.២. លក្ខខណ្ឌនៃការផ្ទៀងផ្ទាត់ឈ្មោះ

ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីកម្មវិធី គ្រួសារក្រីក្រ និងងាយរងគ្រោះ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានប័ណ្ណសមធម៌កម្រិតភាពក្រីក្រ១ ឬកម្រិតភាពក្រីក្រ២ ដែលមានសុពលភាព ហើយស្ថិតនៅក្នុងដំណាក់កាលនៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដូចខាងក្រោម ៖
  + ទីប្រជុំជនក្នុងរាជធានីភ្នំពេញ ៖ ប័ណ្ណសមធម៌ស្ថិតក្នុងការប្រមូលទិន្នន័យជុំទី១
  + ទីប្រជុំជនក្រៅរាជធានីភ្នំពេញ ៖ ប័ណ្ណសមធម៌ស្ថិតក្នុងការប្រមូលទិន្នន័យជុំទី២ ទី៣ និងទី៤
  + ជនបទ ៖ ប័ណ្ណសមធម៌ស្ថិតក្នុងការប្រមូលទិន្នន័យជុំទី១១ ទី១២ និងទី១៣
- បានទៅផ្ទៀងផ្ទាត់ឈ្មោះ ក្នុងកម្មវិធីនៅសាលាឃុំ សង្កាត់ណាមួយ។

## ១.៣. ការឧបត្ថម្ភដល់អ្នកទទួលផល

គ្រួសារក្រីក្រ និងងាយរងគ្រោះដែលបានផ្ទៀងផ្ទាត់ឈ្មោះក្នុងកម្មវិធី ទទួលបានប្រាក់ឧបត្ថម្ភជាកញ្ចប់គ្រួសារ ដូចខាងក្រោម ៖

១. ទីប្រជុំជនក្នុងរាជធានីភ្នំពេញ

| ល.រ. | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធម៌ | ១២០ ០០០រៀល | ១២០ ០០០រៀល |
| ២ | សមាជិកគ្រួសារក្នុងម្នាក់ៗ | ៥២ ០០០រៀល | ៣៦ ០០០រៀល |
| ៣ | កុមារអាយុ ០-៥ឆ្នាំក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០រៀល |
| ៤ | ជនមានពិការភាពក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០រៀល |
| ៥ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០រៀល |
| ៦ | គ្រួសារដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ៤០ ០០០រៀល | ២៨ ០០០រៀល |

២. ទីប្រជុំជនក្រៅរាជធានីភ្នំពេញ

| ល.រ. | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធម៌ | ១២០ ០០០រៀល | ១២០ ០០០រៀល |
| ២ | សមាជិកគ្រួសារក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០រៀល |
| ៣ | កុមារអាយុ ០-៥ឆ្នាំក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០រៀល |
| ៤ | ជនមានពិការភាពក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០រៀល |
| ៥ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០រៀល |
| ៦ | គ្រួសារដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ៤០ ០០០រៀល | ២៨ ០០០រៀល |

៣. ជនបទ

| ល.រ. | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធម៌ | ៨០ ០០០រៀល | ៨០ ០០០រៀល |
| ២ | សមាជិកគ្រួសារក្នុងម្នាក់ៗ | ២៤ ០០០រៀល | ១៦ ០០០រៀល |
| ៣ | កុមារអាយុ ០-៥ឆ្នាំក្នុងម្នាក់ៗ | ២៤ ០០០រៀល | ១៦ ០០០រៀល |
| ៤ | ជនមានពិការភាពក្នុងម្នាក់ៗ | ២៤ ០០០រៀល | ១៦ ០០០រៀល |
| ៥ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ២៤ ០០០រៀល | ១៦ ០០០រៀល |
| ៦ | គ្រួសារដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ២៤ ០០០រៀល | ១៦ ០០០រៀល |

ករណីជនមានពិការភាព ដែលជាកុមារអាយុ ០-៥ឆ្នាំ ឬ មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើង នឹងត្រូវទទួលបានប្រាក់ឧបត្ថម្ភសម្រាប់តែជនមានពិការភាពមួយករណីប៉ុណ្ណោះ។

អ្នកទទួលផលដែលទទួលបានការឧបត្ថម្ភពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះនៅក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅតែបន្តទទួលបានអត្ថប្រយោជន៍ និងអាចទៅចុះឈ្មោះចូលក្នុងកម្មវិធីផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល តាមលក្ខខណ្ឌរបស់កម្មវិធីទាំងនោះ ដើម្បីទទួលបានអត្ថប្រយោជន៍។

គ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលបានផ្ទៀងផ្ទាត់ឈ្មោះក្នុងកម្មវិធី ត្រូវទទួលបានប្រាក់ឧបត្ថម្ភ ផ្អែកតាមទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដោយគិតចាប់ពីថ្ងៃបានផ្ទៀងផ្ទាត់ឈ្មោះនៅឃុំ សង្កាត់ រហូតដល់កម្មវិធីត្រូវបានបញ្ចប់។

## ១.៤. ការផ្ទៀងផ្ទាត់ឈ្មោះ និងការបើកផ្តល់លើកដំបូង

មេឃុំ ចៅសង្កាត់ត្រូវទទួលខុសត្រូវក្នុងការផ្ទៀងផ្ទាត់ឈ្មោះ ដោយចាត់តាំងអ្នកទទួលបន្ទុកកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំនៅឃុំ សង្កាត់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ឈ្មោះតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ ការផ្ទៀងផ្ទាត់ឈ្មោះ ក្នុងកម្មវិធី មានដំណើរការដូចខាងក្រោម ៖

- សមាជិកគ្រួសារក្រីក្រ និងងាយរងគ្រោះដែលមានប័ណ្ណសមធម៌ ត្រូវទៅផ្ទៀងផ្ទាត់ឈ្មោះ ក្នុងកម្មវិធីនៅសាលាឃុំ សង្កាត់ណាមួយ ដោយយកមកជាមួយនូវប័ណ្ណសមធម៌ដែលមានសុពលភាព

ដូចបានបញ្ជាក់នៅចំណុច **១.២** ខាងលើ។ ករណីប័ណ្ណសមធម៌មិនមានរូបថត អ្នកទៅផ្ទៀងផ្ទាត់ឈ្មោះ ត្រូវយកមកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ នៅពេលមកផ្ទៀងផ្ទាត់ឈ្មោះ។ ករណីគ្រួសារក្រីក្រ និងងាយរងគ្រោះដែលមិនអាចមកផ្ទៀងផ្ទាត់ឈ្មោះបាន អាចឱ្យតំណាងស្របច្បាប់ដែលទទួលស្គាល់ពីឃុំ សង្កាត់ មកផ្ទៀងផ្ទាត់ឈ្មោះឱ្យខ្លួនបាន ហើយឃុំ សង្កាត់ត្រូវរាយការណ៍មកក្រុមការងារប្រតិបត្តិកម្មវិធី តាមរយៈមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវធ្វើការផ្ទៀងផ្ទាត់ឈ្មោះ តាមអែប(App) របស់កម្មវិធី ដោយបញ្ចូលលេខប័ណ្ណសមធម៌ លេខទូរស័ព្ទ(បើមាន) និងថតរូបអ្នកមកផ្ទៀងផ្ទាត់ឈ្មោះដោយមានកាន់ប័ណ្ណសមធម៌ រួចបញ្ជូនព័ត៌មានទាំងនោះ តាមអែប(App)របស់កម្មវិធីចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដើម្បីផ្តល់ការបើកផ្តល់លើកដំបូងដល់អ្នកទទួលផល។
- នៅពេលផ្ទៀងផ្ទាត់ឈ្មោះរួច អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវផ្តល់ព័ត៌មានដល់អ្នកទទួលផលអំពីចំនួនប្រាក់ឧបត្ថម្ភសរុបប្រចាំខែ កាលបរិច្ឆេទនៃការបើកប្រាក់បន្ទាប់ ការបើកប្រាក់នៅបញ្ជរវីង និងការយកប័ណ្ណសមធម៌ទៅជាមួយនៅពេលបើកប្រាក់។ ក្នុងករណី អ្នកទទួលផលមានសំណួរ អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវធ្វើការស្រាយបំភ្លឺ។
- បន្ទាប់ពីបានផ្ទៀងផ្ទាត់ឈ្មោះរួច អ្នកទទួលផលអាចទៅបើកប្រាក់ឧបត្ថម្ភនៅបញ្ជរវីងណាមួយ ដោយយកទៅជាមួយនូវប័ណ្ណសមធម៌។ អ្នកទទួលផលមិនអាចឱ្យអ្នកដទៃ ក្រៅពីសមាជិកគ្រួសារដែលមានឈ្មោះក្នុងប្រព័ន្ធ ឬតំណាងស្របច្បាប់ដែលទទួលស្គាល់ពីឃុំ សង្កាត់ ទៅបើកប្រាក់ឧបត្ថម្ភជំនួសខ្លួនឡើយ។ ករណីអនុវត្តផ្ទុយពីនេះ អ្នកទទួលផល និងអ្នកពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។
- ភ្នាក់ងារធនាគារឯកទេសវីង ត្រូវផ្ទៀងផ្ទាត់លេខគណនីធនាគារ ដោយប្រើប្រាស់លេខប័ណ្ណសមធម៌ និងបញ្ចូលលេខសម្ងាត់ដំបូង បន្ទាប់មក ឱ្យអ្នកទទួលផលប្តូរលេខសម្ងាត់គណនីធនាគាររបស់ខ្លួនដោយខ្លួនឯង(លេខសម្ងាត់គណនីធនាគារនេះ ត្រូវប្រើប្រាស់សម្រាប់ការបើកប្រាក់លើកក្រោយទៀត) និងថតរូបអ្នកបើកប្រាក់ដោយមានកាន់ប័ណ្ណសមធម៌ រួចបញ្ជូនរូបថតនោះចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន មុននឹងផ្តល់ប្រាក់ជូនអ្នកទទួលផល។

## ១.៥. ការបើកផ្តល់លើកបន្ទាប់

នៅខែបន្ទាប់ អ្នកទទួលផលត្រូវទៅបើកប្រាក់ឧបត្ថម្ភប្រចាំខែ ដូចខាងក្រោម ៖

- អ្នកទទួលផលត្រូវទៅបើកប្រាក់ឧបត្ថម្ភនៅតាមបញ្ជរវីងណាមួយ ដោយយកទៅជាមួយនូវប័ណ្ណសមធម៌។
- ភ្នាក់ងារធនាគារឯកទេសវីង ផ្ទៀងផ្ទាត់លេខគណនីធនាគារដោយប្រើប្រាស់លេខប័ណ្ណសមធម៌ បន្ទាប់មក ឱ្យអ្នកទទួលផលវាយលេខសម្ងាត់គណនីធនាគាររបស់ខ្លួន និងថតរូបអ្នកបើកប្រាក់ដោយមានកាន់ប័ណ្ណសមធម៌ រួចបញ្ជូនរូបថតនោះចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន មុននឹងផ្តល់ប្រាក់ជូនអ្នកទទួលផល។

# ជំពូកទី២
# ការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី

ការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី ត្រូវប្រើប្រាស់យន្តការដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដោយបន្ថែមការទទួលខុសត្រូវ ដូចខាងក្រោម ៖

## ២.១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុស ត្រូវក្នុងការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី ដូចខាងក្រោម ៖

- ត្រួតពិនិត្យវឌ្ឍនភាព និងការអនុវត្តកម្មវិធីប្រចាំថ្ងៃ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- រៀបចំកិច្ចប្រជុំជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬរដ្ឋបាលឃុំ សង្កាត់ និងភាគីពាក់ព័ន្ធ តាមការចាំបាច់ ដើម្បីគាំទ្រ និងកែលម្អការអនុវត្តកម្មវិធី
- តាមដានត្រួតពិនិត្យទិន្នន័យ តាមប្រព័ន្ធអនឡាញ សម្រាប់ពង្រឹងការអនុវត្តកម្មវិធី
- រៀបចំអង្កេតបឋមសម្រាប់រៀបចំទិន្នន័យដើមគ្រា និងផលប៉ះពាល់របស់កម្មវិធី
- រៀបចំរបាយការណ៍វឌ្ឍនភាព និងការបញ្ចប់ការអនុវត្តកម្មវិធីជូនក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ២.២. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី ដូចខាងក្រោម ៖

- ត្រួតពិនិត្យវឌ្ឍនភាព និងការអនុវត្តកម្មវិធីប្រចាំថ្ងៃ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- រៀបចំកិច្ចប្រជុំជាមួយឃុំ សង្កាត់ និងភាគីពាក់ព័ន្ធ តាមការចាំបាច់ ដើម្បីគាំទ្រ និងកែលម្អការអនុវត្តកម្មវិធី
- ចុះតាមដានត្រួតពិនិត្យ(ឃុំ សង្កាត់យ៉ាងតិច១០ឃុំ សង្កាត់ក្នុងមួយខែ និងអ្នកទទួលផលយ៉ាងតិច១%ក្នុងមួយខែ) ដោយកត់ត្រាលទ្ធផលតាមដានត្រួតពិនិត្យតាមប្រព័ន្ធអនឡាញ
- ចូលរួមក្នុងដំណើរការតាមដានត្រួតពិនិត្យ និងការធ្វើអង្កេត
- រាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមទៅរដ្ឋបាលរាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ២.៣. ឃុំ សង្កាត់

ឃុំ សង្កាត់ទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី ដូចខាងក្រោម ៖

- តាមដានត្រួតពិនិត្យការចូលរួមអនុវត្តកម្មវិធីរបស់អ្នកទទួលផល
- ត្រួតពិនិត្យការផ្ទៀងផ្ទាត់ឈ្មោះ ដើម្បីធានាថាព័ត៌មានអ្នកទទួលផលមានភាពត្រឹមត្រូវ
- រាយការណ៍បញ្ហាប្រឈម និងបណ្ដឹងតវ៉ា ដែលមិនអាចដោះស្រាយបាន មកមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីដោះស្រាយ។

# ជំពូកទី៣
# យន្តការដោះស្រាយបណ្តឹងតវ៉ា

## ៣.១. យន្តការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកទទួលផល

យន្តការនេះសំដៅលើការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកទទួលផល បន្ទាប់ពីបានផ្ទៀងផ្ទាត់ឈ្មោះរួច ពាក់ព័ន្ធនឹងការបាត់ ឬខូចប័ណ្ណសមធម៌ មិនអាចបើកប្រាក់ឧបត្ថម្ភបាន ប្រាក់ឧបត្ថម្ភមិនបានបញ្ចូលក្នុងគណនី ភ្លេចពាក្យសម្ងាត់ និងបញ្ហាផ្សេងៗទៀត។ អ្នកទទួលផលដែលមានបំណងប្តឹងតវ៉ាអាចដាក់ពាក្យប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរ ឬជាពាក្យសំដីដោយផ្ទាល់ទៅរដ្ឋបាលឃុំ សង្កាត់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកទទួលផល មានដូចខាងក្រោម ៖

- **ឃុំ សង្កាត់ ៖** បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ា អ្នកទទួលបន្ទុកកម្មវិធីត្រូវស្នើសុំយោបល់ពីមេឃុំ ចៅសង្កាត់ ដើម្បីពិនិត្យ ស៊ើបអង្កេត និងធ្វើការដោះស្រាយ មិនឱ្យលើសរយៈពេល១ថ្ងៃ បន្ទាប់ពីទទួលបានពាក្យបណ្តឹង។ ករណីបណ្តឹងតវ៉ានោះមិនអាចដោះស្រាយបាន អ្នកទទួលបន្ទុកកម្មវិធីត្រូវបញ្ជូនពាក្យបណ្តឹងតវ៉ាទាំងនោះ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន មកមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្នើសុំជួយដោះស្រាយ។
- **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖** បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ាពីអ្នកប្តឹង ឬឃុំ សង្កាត់ មន្ត្រីប្រតិបត្តិកម្មវិធីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវពិនិត្យ ស៊ើបអង្កេត និងធ្វើការដោះស្រាយ មិនឱ្យលើសរយៈពេល១ថ្ងៃ បន្ទាប់ពីទទួលបានពាក្យបណ្តឹង។ ករណីបណ្តឹងតវ៉ានោះមិនអាចដោះស្រាយបាន មន្ត្រីប្រតិបត្តិកម្មវិធីត្រូវបញ្ជូនពាក្យបណ្តឹងតវ៉ាទាំងនោះ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្នើសុំជួយដោះស្រាយ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖** បន្ទាប់ពីទទួលបានពាក្យបណ្តឹងតវ៉ាពីអ្នកប្តឹង ឬមន្ត្រីប្រតិបត្តិកម្មវិធីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមការងារប្រតិបត្តិកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវពិនិត្យ ស៊ើបអង្កេត និងធ្វើការដោះស្រាយ។ លទ្ធផលនៃការដោះស្រាយរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាលទ្ធផលស្ថាពរ។
- បន្ទាប់ពីបានដោះស្រាយរួច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្តល់ព័ត៌មានទៅឱ្យមេឃុំ ចៅសង្កាត់ តាមរយៈ យន្តការដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។ មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងអំពីលទ្ធផលនៃការដោះស្រាយជូនអ្នកប្តឹងតវ៉ា។

ករណីគ្រួសារក្រីក្រ និងងាយរងគ្រោះមានបញ្ហាពាក់ព័ន្ធនឹងការមិនមានប័ណ្ណសមធម៌ ប័ណ្ណសមធម៌ផុតសុពលភាព ឬបាត់ប័ណ្ណសមធម៌ ឬបណ្តឹងតវ៉ាផ្សេងៗមុនពេលផ្ទៀងផ្ទាត់ឈ្មោះ ត្រូវដោះស្រាយតាមយន្តការរបស់ស្ថាប័នពាក់ព័ន្ធ ដូចខាងក្រោម ៖

- ករណីគ្រួសារក្រីក្រ និងងាយរងគ្រោះមិនមានប័ណ្ណសមធម៌ ឬប័ណ្ណសមធម៌ផុតសុពលភាព ឬបាត់ប័ណ្ណសមធម៌ត្រូវដោះស្រាយតាមយន្តការរបស់ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ
- ករណីគ្រួសារក្រីក្រ និងងាយរងគ្រោះដែលមានប័ណ្ណសមធម៌ ហើយមិនអាចមកផ្ទៀងផ្ទាត់ឈ្មោះក្នុងកម្មវិធី ត្រូវដោះស្រាយដោយប្រើប្រាស់យន្តការរដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់
- ករណីគ្រួសារក្រីក្រ និងងាយរងគ្រោះដែលមានប័ណ្ណសមធម៌ ហើយមានវិវាទគ្រួសារ ដែលបង្កការរារាំងដល់ការផ្ទៀងផ្ទាត់ឈ្មោះ ត្រូវដោះស្រាយដោយប្រើប្រាស់យន្តការរដ្ឋបាលរបស់រដ្ឋបាលឃុំ សង្កាត់
- ករណីអ្នកទទួលផលទទួលមរណភាព ក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធី ហើយអ្នកទទួលផលនោះមិនមានសមាជិកគ្រួសារទទួលផលបន្ត ប្រាក់ឧបត្ថម្ភនោះនឹងត្រូវបង្វិលចូលកញ្ចប់ថវិការបស់កម្មវិធី។

## ៣.២. ការដោះស្រាយការប្រព្រឹត្តមិនត្រឹមត្រូវរបស់មន្ត្រីកម្មវិធី

ការដោះស្រាយការប្រព្រឹត្តមិនត្រឹមត្រូវរបស់មន្ត្រីកម្មវិធី ត្រូវប្រើប្រាស់យន្តការដែលមានស្រាប់របស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដោយបន្ថែមការទទួលខុសត្រូវដូចខាងក្រោម ៖

- អ្នកប្ដឹងត្រូវដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរ និងភ្ជាប់មកជាមួយនូវភស្ដុតាង ដោយដាក់ក្នុងស្រោមសំបុត្របិតជិតទៅឃុំ សង្កាត់ ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- នៅពេលទទួលបានពាក្យបណ្ដឹង មេឃុំ ចៅសង្កាត់ ត្រូវបញ្ជូនពាក្យបណ្ដឹងទាំងនោះ ទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- នៅពេលទទួលបានពាក្យបណ្ដឹងពីអ្នកប្ដឹង ឬមេឃុំ ចៅសង្កាត់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវបញ្ជូនពាក្យបណ្ដឹងទាំងនោះ ទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីដោះស្រាយ
- នៅពេលទទួលបានពាក្យបណ្ដឹងពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋបាលរាជធានី ខេត្ត ត្រូវសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការណ៍ដោះស្រាយ។ ករណីបណ្ដឹងមិនអាចដោះស្រាយបាន រដ្ឋបាលរាជធានី ខេត្តត្រូវបញ្ជូនបណ្ដឹងទាំងនោះទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- នៅពេលទទួលបានពាក្យបណ្ដឹងពីរដ្ឋបាលរាជធានី ខេត្ត ក្រុមប្រតិបត្តិកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការចាត់វិធានការណ៍ដោះស្រាយ ស្របតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា។

ករណី រកឃើញការប្រព្រឹត្តមិនត្រឹមត្រូវរបស់របស់មន្ត្រីកម្មវិធី ក្នុងអំឡុងពេលនៃការចុះតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី ក្រុមការងារតាមដានត្រួតពិនិត្យនោះ ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់មកនូវភស្ដុតាង មកក្រុមប្រតិបត្តិកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចាត់វិធានការណ៍តាមនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ៣.៣. ការដោះស្រាយការប្រព្រឹត្តមិនត្រឹមត្រូវរបស់ស្ថាប័នបើកផ្ដល់

ករណី មានការបណ្ដឹង ឬរកឃើញថា ស្ថាប័នប្រព្រឹត្តមិនត្រឹមត្រូវ ត្រូវដោះស្រាយតាមយន្តការដែលបានកំណត់នៅក្នុងអនុស្សរណៈយោគយល់រវាងស្ថាប័នបើកផ្ដល់ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៤
# យន្តការគាំទ្រការអនុវត្តកម្មវិធី

យន្តការគាំទ្រនៃការអនុវត្តកម្មវិធីនេះត្រូវប្រើប្រាស់យន្តការដែលមានស្រាប់ ក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដោយបន្ថែមការទទួលខុសត្រូវ ដូចខាងក្រោម ៖

## ៤.១. ស្ថាប័នថ្នាក់ជាតិ

### ក. ក្រុមប្រឹក្សាជាតិគាំពារសង្គម

ក្រុមប្រឹក្សាជាតិគាំពារសង្គមទទួលខុសត្រូវ ដូចខាងក្រោម ៖

- សម្របសម្រួលកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធី
- ផ្ដល់ការតម្រង់ទិសផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការអនុវត្តកម្មវិធី
- ពិនិត្យតាមដាន និងផ្ដល់យោបល់លើការអនុវត្តកម្មវិធី។

### ខ .ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវ ដូចខាងក្រោម ៖

- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី
- រៀបចំផែនការសកម្មភាព គម្រោងថវិកា ឯកសារគតិយុត្តិ និងយន្តការក្នុងការអនុវត្តកម្មវិធី
- ផ្សព្វផ្សាយការយល់ដឹងអំពីកម្មវិធីដល់សាធារណជន និងអ្នកទទួលផល
- គាំទ្រ និងផ្ដល់បច្ចេកទេសដល់ឃុំ សង្កាត់ និងមន្ទីរស.អ.យ. ក្នុងការអនុវត្តកម្មវិធី
- សហការជាមួយស្ថាប័នធនាគារ ក្នុងការផ្ដល់សេវាផ្ទេរសាច់ប្រាក់ជូនអ្នកទទួលផល
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- តាមដានត្រួតពិនិត្យ និងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធី។

### គ .ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវ ដូចខាងក្រោម ៖

- ត្រួតពិនិត្យ ផ្ដល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់ការអនុវត្តកម្មវិធី
- គាំទ្រ និងសម្របសម្រួលការវិភាជន៍ថវិកាសម្រាប់ឧបត្ថម្ភសាច់ប្រាក់ជូនអ្នកទទួលផល
- ពិនិត្យរបាយការណ៍សកម្មភាពការងារ និងការអនុវត្តថវិការបស់កម្មវិធី
- ចូលរួមពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធី។

### ឃ .ក្រសួងផែនការ

ក្រសួងផែនការទទួលខុសត្រូវ ដូចខាងក្រោម ៖

- ផ្ដល់ទិន្នន័យគ្រួសារក្រីក្រ ដើម្បីកំណត់ការឧបត្ថម្ភសាច់ប្រាក់ជូនអ្នកទទួលផល
- គាំទ្រឃុំ សង្កាត់ ក្នុងការអនុវត្តយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ តាមការស្នើសុំ
- គាំទ្រផ្នែកបច្ចេកទេស ក្នុងការបញ្ចូលទិន្នន័យគ្រួសារក្រីក្រក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន

- សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍ ដើម្បីគាំទ្រការអនុវត្តកម្មវិធី
- ចូលរួមកសាងសមត្ថភាព ពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាក្នុងការអនុវត្តកម្មវិធី
- ដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- ចេញប័ណ្ណសមធម៌ទុតិយតាដល់អ្នកទទួលផលដែលបាត់ប័ណ្ណ ដើម្បីបន្តបានបើកផ្តល់ពីកម្មវិធី។

**ខ .ក្រសួងមហាផ្ទៃ**

ក្រសួងមហាផ្ទៃទទួលខុសត្រូវ ដូចខាងក្រោម៖

- ពង្រឹងយន្តការដែលមានស្រាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគាំទ្រការអនុវត្តកម្មវិធី
- សហការ និងចូលរួមផ្សព្វផ្សាយការយល់ដឹងអំពីកម្មវិធីដល់សាធារណជន និងអ្នកទទួលផល
- សហការក្នុងការពិនិត្យ តាមដាន វាយតម្លៃ និងដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធី
- ជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពន្លឿន និងធ្វើឱ្យមានសុក្រឹតភាពលើការវាយតម្លៃ និងកំណត់អ្នកទទួលផល តាមការណែនាំបច្ចេកទេសរបស់ក្រសួងផែនការ។

## ៤.២. ស្ថាប័នថ្នាក់ក្រោមជាតិ

**ក. រដ្ឋបាលរាជធានី ខេត្ត**

រដ្ឋបាលរាជធានី ខេត្តទទួលខុសត្រូវ ដូចខាងក្រោម ៖

- គាំទ្រ និងចូលរួមផ្សព្វផ្សាយការយល់ដឹងអំពីកម្មវិធីដល់សាធារណជន និងអ្នកទទួលផល
- សហការ និងចូលរួមបង្កើនសមត្ថភាពដល់ឃុំ សង្កាត់ និងមន្ត្រីពាក់ព័ន្ធនឹងកម្មវិធី
- គាំទ្រ និងពង្រឹងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការគាំទ្រការអនុវត្តកម្មវិធី
- គាំទ្រ និងពង្រឹងរដ្ឋបាលឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី
- ចូលរួមតាមដានត្រួតពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបញ្ហាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ខ. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវ ដូចខាងក្រោម ៖

- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី
- ផ្សព្វផ្សាយការយល់ដឹងអំពីកម្មវិធីដល់សាធារណជន និងអ្នកទទួលផល
- បង្កើនសមត្ថភាព និងគាំទ្របច្ចេកទេសដល់ឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- តាមដានត្រួតពិនិត្យ និងរាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីដល់រដ្ឋបាលរាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**គ .មន្ទីរផែនការរាជធានី ខេត្ត**

មន្ទីរផែនការរាជធានី ខេត្តទទួលខុសត្រូវ ដូចខាងក្រោម ៖

- គាំទ្រឃុំ សង្កាត់ក្នុងការអនុវត្តយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ តាមការស្នើសុំ
- គាំទ្រឃុំ សង្កាត់ក្នុងការធ្វើបច្ចុប្បន្នភាពការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ តាមជុំ

- ចូលរួមកសាងសមត្ថភាព ពិនិត្យតាមដាន និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ឃ. រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

រដ្ឋបាលក្រុង ស្រុក ខណ្ឌទទួលខុសត្រូវ ដូចខាងក្រោម ៖

- គាំទ្រ និងចូលរួមផ្សព្វផ្សាយការយល់ដឹងអំពីកម្មវិធីដល់សាធារណជន និងអ្នកទទួលផល
- សហការ និងចូលរួមបង្កើនសមត្ថភាពដល់ឃុំ សង្កាត់ និងមន្ត្រីពាក់ព័ន្ធនឹងកម្មវិធី
- ជំរុញ និងពង្រឹងរដ្ឋបាលឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី
- ចូលរួមតាមដានត្រួតពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបញ្ហាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី។

**ង. រដ្ឋបាលឃុំ សង្កាត់**

រដ្ឋបាលឃុំ សង្កាត់ទទួលខុសត្រូវ ដូចខាងក្រោម ៖

- ដឹកនាំ និងគ្រប់គ្រងដំណើរការអនុវត្តកម្មវិធីនៅឃុំ សង្កាត់
- ផ្សព្វផ្សាយការយល់ដឹងអំពីកម្មវិធីដល់អ្នកទទួលផល និងអ្នកពាក់ព័ន្ធ
- ផ្ទៀងផ្ទាត់ឈ្មោះ និងផ្តល់ការបើកផ្តល់លើកដំបូង
- ទទួល និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកទទួលផល
- តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- បញ្ជាក់ និងវាយតម្លៃលើការផ្តល់ប័ណ្ណសមធម៌សម្រាប់ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមជុំ និងតាមការស្នើសុំ
- រាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជូនរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរស.អ.យ.។

# ជំពូកទី៥
# របៀបប្រើប្រាស់មុខងារបន្ថែមរបស់អែប( App )

## ៥.១. ការផ្ទៀងផ្ទាត់ឈ្មោះ និងការបើកផ្តល់លើកដំបូង

### ក. ការចូលប្រើប្រាស់កម្មវិធី

ស្វែងរកអែបរបស់កម្មវិធីក្នុងតាប្លេត ដែលមាន រូប រួចចុចពីលើរូបនោះ អេក្រង់បង្ហាញផ្ទាំង "**ចូលប្រើប្រាស់កម្មវិធី**" បន្ទាប់មក ៖

១. វាយឈ្មោះអ្នកប្រើប្រាស់របស់អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់។

២. វាយពាក្យសម្ងាត់របស់អ្នកប្រើប្រាស់ (អ្នកទទួលបន្ទុកកម្មវិធី)។

៣. ចុចប៊ូតុង"**ចូល**" បន្ទាប់មក អេក្រង់បង្ហាញផ្ទាំង "**មុខងារកម្មវិធី**" ដូចខាងក្រោម។




### ខ. ចូលប្រើប្រាស់មុខងារឧបត្ថម្ភអំឡុងកូវីដ-១៩




ស្វែងរកមុខងារឧបត្ថម្ភអំឡុងកូវីដ-១៩ ដែលមាន រូប រួច ៖

១. ចុចលើរូប អេក្រង់បង្ហាញផ្ទាំងសារ "**ផ្ទៀងផ្ទាត់អ្នកទទួលផល**"ដូចខាងក្រោម ៖




២. វាយលេខប័ណ្ណសមធម៌ចូល xxxxxx-xxxx

៣. ចុចប៊ូតុង "**ស្វែងរក**" នោះអេក្រង់បង្ហាញផ្ទាំង "**ផ្ទៀងផ្ទាត់ និងការបើកផ្តល់លើកដំបូង**"។ ករណីចុច "**បិទ**" អេក្រង់បង្ហាញផ្ទាំង"**មុខងារកម្មវិធី**" វិញ។

## គ. ការផ្ទៀងផ្ទាត់ឈ្មោះ



នៅលើផ្ទាំង"**ការផ្ទៀងផ្ទាត់ និងការបើកផ្តល់លើកដំបូង**" បង្ហាញព័ត៌មានអ្នកទទួលផលដូចខាងក្រោម ៖

- លេខប័ណ្ណសមធម៌ និងឈ្មោះអ្នកទទួលផល
- កម្រិតភាពក្រីក្រ និងតំបន់
- ឈ្មោះសមាជិក
- ប្រាក់ឧបត្ថម្ភទទួលបាន
- អាសយដ្ឋាន
- រូបថតអ្នកទទួលផលដែលបានថតរួចក្នុងប័ណ្ណសមធម៌ (អាចមិនមាន)

អ្នកទទួលបន្ទុកកម្មវិធីត្រូវ ៖

១. បំពេញលេខទូរស័ព្ទអ្នកមកផ្ទៀងផ្ទាត់ឈ្មោះ

២. ចុចលើប្រអប់ដែលមានរូបម៉ាស៊ីនថត អេក្រង់បង្ហាញផ្ទាំងថតរូប ដែលត្រូវ ៖

- ចុចសញ្ញា ដើម្បីថតរូប
- ចុចសញ្ញា ✓ យល់ព្រមយករូបថត
- ចុចសញ្ញា × លុបរូបដែលបានថត
- ចុចសញ្ញា ថតឡើងវិញ



៣. ចុចប៊ូតុង"**បើកផ្តល់**" អេក្រង់បង្ហាញផ្ទាំងសារ "**បញ្ជាក់ការផ្ទៀងផ្ទាត់**"។ ករណីចុចប៊ូតុង "**ចាកចេញ**"អេក្រង់បង្ហាញ"**ផ្ទាំងមុខងារ**"វិញ។

៤. នៅលើផ្ទាំងសារ"**បញ្ជាក់ការផ្ទៀងផ្ទាត់**" ត្រូវចុចប៊ូតុង"**យល់ព្រម**" អេក្រង់នឹងបង្ហាញផ្ទាំងសារ "**ផ្ទៀងផ្ទាត់**"។ ករណីចុចប៊ូតុង"**មិនយល់ព្រម**"អេក្រង់នឹងបង្ហាញផ្ទាំង"**ការផ្ទៀងផ្ទាត់ និងការបើកផ្តល់លើកដំបូង**"វិញ។






៥. នៅលើផ្ទាំងសារ"**ផ្ទៀងផ្ទាត់**" ត្រូវចុចប៊ូតុង"**បិទ**" អេក្រង់នឹងបង្ហាញ "**ផ្ទាំងមុខងារ**" នៅលើ "ផ្ទាំងមុខងារ"ចុចប៊ូតុង"បិទ"ដែលមានរូប ដើម្បីចាកចេញពីកម្មវិធី។

## ៥.២. បណ្ដឹងតវ៉ារបស់អ្នកទទួលផល

### ក. ការចូលប្រើប្រាស់កម្មវិធី

ស្វែងរកអែបរបស់កម្មវិធី ដែលមានរូប  រួចចុចពីលើរូបនេះ អេក្រង់បង្ហាញផ្ទាំង"**ចូលប្រើប្រាស់កម្មវិធី**"។

១. វាយឈ្មោះអ្នកប្រើប្រាស់របស់អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់។

២. វាយពាក្យសម្ងាត់របស់អ្នកប្រើប្រាស់

៣. ចុចប៊ូតុង"**ចូល**" បន្ទាប់មក អេក្រង់បង្ហាញផ្ទាំង"**មុខងារកម្មវិធី**"ដូចខាងក្រោម។




### ខ. ចូលប្រើប្រាស់មុខងារបណ្ដឹងតវ៉ា កូវីដ-១៩



ស្វែងរកមុខងារបណ្ដឹងតវ៉ា និងក្លែងបន្លំ ដែលមានរូប  រួច ៖

១. ចុចពីលើរូប  អេក្រង់នឹងបង្ហាញផ្ទាំងមុខងារ ដូចខាងក្រោម ៖



២. ចុចលើមុខងារ"**បណ្ដឹងតវ៉ាកូវីដ-១៩**"ដែលមានរូប  បន្ទាប់មក អេក្រង់បង្ហាញផ្ទាំងសារ "**អនុវត្តដំណោះស្រាយបញ្ហា**" ។




៣. នៅលើផ្ទាំង "**អនុវត្តដំណោះស្រាយបញ្ហា**" វាយលេខប័ណ្ណសមធម៌ចូល(xxxxxx-xxxx)

៤. ចុចប៊ូតុង "**ស្វែងរក**" អេក្រង់បង្ហាញផ្ទាំង"**បណ្ដឹងតវ៉ារបស់អ្នកទទួលផល**"។ ករណីចុច "**បិទ**" អេក្រង់បង្ហាញផ្ទាំង"**មុខងារកម្មវិធី**" វិញ។

**គ. ការបំពេញព័ត៌មានបណ្តឹងតវ៉ា**

នៅលើផ្ទាំង "**បណ្តឹងតវ៉ារបស់អ្នកទទួលផល**" អេក្រង់បង្ហាញព័ត៌មានអ្នកទទួលផល ដូចខាងក្រោម ៖

- លេខប័ណ្ណសមធម៌
- ឈ្មោះអ្នកទទួលផល
- អាស័យដ្ឋាន




មន្ត្រីទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវបំពេញព័ត៌មាន ដូចខាងក្រោម ៖

១. ចុចជ្រើសរើសប្រភេទអ្នកដាក់បណ្តឹង

២. បំពេញឈ្មោះអ្នកទទួលបណ្តឹង

៣. ចុចជ្រើសរើសតួនាទីអ្នកដោះស្រាយ។ ករណីចុចផ្សេងៗ នឹងបង្ហាញប្រឡោះសម្រាប់បំពេញព័ត៌មាន

៤. ចុចជ្រើសរើសប្រភេទបណ្តឹងតវ៉ា។ ករណីចុចផ្សេងៗ នឹងបង្ហាញប្រឡោះសម្រាប់បំពេញប្រភេទបណ្តឹង

៥. ចុចជ្រើសរើសលទ្ធផលដោះស្រាយបណ្តឹងតវ៉ា។ ករណីចុចផ្សេងៗ នឹងបង្ហាញប្រឡោះសម្រាប់បំពេញលទ្ធផលដោះស្រាយបណ្តឹងតវ៉ា

៦. ចុចប៊ូតុង "**បញ្ជូន**" ព័ត៌មានបណ្តឹងតវ៉ាទាំងនោះ នឹងបញ្ជូនចូលប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ហើយអេក្រង់នឹងបង្ហាញផ្ទាំង"**មុខងារ**"វិញ។ ករណីចុចប៊ូតុង "**បោះបង់**" ព័ត៌មានដែលបានបំពេញរួច មិនត្រូវបានបញ្ជូនចូលប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានឡើយ ហើយអេក្រង់នឹងបង្ហាញផ្ទាំង "**មុខងារ**"វិញ។